# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

# ការបញ្ជាក់គុណភាពគ្រាប់ពូជ

**រៀបចំដោយ**


លោក ប៉ង់ ប៉ូរ៉ា ការិយាល័យគ្រប់គ្រងនិងអភិវឌ្ឍន៍ពូជស្រូវ

*ទូរស័ព្ទ ៖ ០១២ ៨៨២ ៤៨៥, ០៩៧ ៦០៨ ៦០៨ ៣*


*ថ្ងៃទី ២៨ វិច្ឆិកា ឆ្នាំ២០១៤*

# ការបញ្ជាក់គុណភាពគ្រាប់ពូជ

**គោលបំណង** (objectives) ៖ ដើម្បីឱ្យសិក្ខាកាមយល់ដឹងពី

- កត្តាប៉ះពាល់ដល់គុណភាពគ្រាប់ពូជ
- ចំណាត់ថ្នាក់គ្រាប់ពូជ
- ការធ្វើតេស្តគុណភាពគ្រាប់ពូជ
- គន្លឹះសំខាន់ៗដែលធ្វើឱ្យគុណភាពគ្រាប់ពូជប្រសើរឡើង

**លទ្ធផលរំពឹងទុក** ៖ នៅចុងបញ្ចប់សិក្ខាកាមនឹងមានលទ្ធភាព

- កំណត់គុណភាពគ្រាប់ពូជ
- យល់ដឹងពីកត្តាប៉ះពាល់ដល់គុណភាពគ្រាប់ពូជ
- ធ្វើឱ្យគុណភាពគ្រាប់ពូជប្រសើរឡើង

# ១. កត្តាប៉ះពាល់ដល់គុណភាពគ្រាប់ពូជ

គុណភាពគ្រាប់ពូជគឺជាការប្រមូលផ្តុំនូវកត្តាជាច្រើន ដែលបែងចែកទៅតាមរូបរាង ទម្រង់គ្រាប់និងអាស្រ័យទៅលើលក្ខណៈរូបសាស្រ្តដែលរុក្ខជាតិបានផ្តល់ឱ្យក្នុងកំឡុងពេលលូតលាស់ ប្រមូលផល កិច្ចប្រតិបត្តិការផ្សេងៗ និងការទុកដាក់។ សីតុណ្ហភាព ដីជាតិដី និងកត្តាបរិស្ថានក៏ជះឥទ្ធិពលលើការលូតលាស់ និងគុណភាពផងដែរ។

# ២. ចំណាត់ថ្នាក់គ្រាប់ពូជ

- គ្រាប់ពូជសុទ្ធជម្រើសវិទូ(BS)
- គ្រាប់ពូជសុទ្ធគ្រឹះ(FS)
- គ្រាប់ពូជសុទ្ធទទួលស្គាល់(RS)
- គ្រាប់ពូជសុទ្ធអនុញ្ញាត(CS)
- គ្រាប់ពូជសុទ្ធល្អ(GS)